# ការសំភាសន៍របស់បង ស៊ុន ពុធី

កះ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ាវ ខះ អ្នកដែរអោយគេសំភាសន៍ ស៊ុន ពុធី

## <u>ការសង្ខេបប្រវត្តិរបស់បង ស៊ុន ពុធី</u>

បងស្រី ស៊ុន ពុធី មានអាយុ38ឆ្នាំ នៅក្នុងឆ្នាំ2018។បងស្រី ស៊ុន ពុធី មានភេទស្រី ។បងស្រី ពុធី មានទីលំនៅបច្ចុប្បន្ននៅភូមិដក់ពរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

កះ ចឹងជាដំបូងខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង ហើយការសំភាសន៍នេះ ត្រូវបានរៀបចំឡើងដោយសកលវិទ្យល័យមួយដែរនៅអាមេរិចដែរមានឈ្មោះBYUចឹង ហើយដាយសារ តែសកលវិទ្យាល័យមានគោបំណាងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូបនចៅជំនាន់ក្រោយៗ អោយពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយនឹងប្រវត្តិរបស់ដូនតាចឹងហាសបង ហើយនៅពេលដែរខ្ញុំសំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាស ចឹងតើបងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេ ?

ខះ អត់អីទេអូនដាក់ចុះ

កះ ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍បង ខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍មីងគឺធ្វើនៅ ថ្ងៃទី12 ខែ3 ឆ្នាំ2018 គឺសំភាសន៍នៅភូមិអីគេ?

ខះ ភូមិដក់ពរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

កះ អូ៎!បាទមីងខ្ញុំបានសំភាសន៍ជាង10នាក់ហើយនឹងនៅតែភ្លេចដដែរនឹង ចុះសំរាប់ឈ្មោះបងឈ្មោះពេញនឹងឈ្មោះអីគេដែរបង?

ខះ ឈ្មោះពេញរបស់បងមានឈ្មោះថាស៊ុន ពុធី

កៈ ចុះមានឈ្មោះហៅក្រៅដែរទេបង?

ខៈ បើនៅខាងក្រៅនឹងតែបងធីនឹង

កៈ ចុះកាលបងនៅពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះមីងអីផ្សេងដែរទេមីង?

ខៈ អត់មានទេអូន

កៈ ចុះបងសព្វថ្ងៃនឹងបងអាយុប៉ុន្មានដែរមីង?

ខៈ បងសព្វថ្ងៃនឹងបងអាយុ38ឆ្នាំ

កៈ បងអាយុ38ឆ្នាំណាបង ចុះបងកើតនៅថ្ងៃខែឆ្នាំណាបងមានចងចាំទេ?

ខៈ ខ្ញុំចាំតើ ថ្ងៃទី17 ខែ5 ឆ្នាំ1979

កៈ ឆ្នាំ1979 អូ ដាច់ពលពតហើយណាបង?

ខៈ ចា៎!ដាច់ពលពតហើយខ្ញុំបងហោស

កៈ ចុះបងកើតនៅភូមិឃុំស្រុកអីគេដែរបង?

ខៈ បងកើតនៅភូមិដក់ពរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

កៈ អ៊ូ!កើតនៅទីនេះតែម្តងហោសបង?

ខៈ ចា៎!នៅនឹង

កៈ ចុះសំរាប់បងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរបង?

ខៈ បងមានបងប្អូនចំនួន5នាក់

កៈ បងប្អូនរបស់បងនឹងមានស្រីប៉ុន្មាន នឹងប្រុសប៉ុន្មានដែរបង?

ខៈ មានស្រី3នាក់ នឹងប្រុស2នាក់

កៈ ចុះបងជាកូនទីប៉ុន្មានដែរបង?

ខៈ បងជាកូនទី1

កៈ ចុះបងអាចប្រាប់ពីឈ្មោះបងប្អូនរបស់បងបានទេ?

ខ៖  បងអាចប្រាប់បានតើ! កូនទី1 បងឈ្មោះស៊ុន ពុធី

ក៖  ចុះទី2វិញបង?

ខ៖  កូនទី2នឹងស្រីឈ្មោះស៊ុន សាធិ, កូនទី3ឈ្មោះស៊ុន សាធា

ក៖  អ៊ូ!ឈ្មោះ សាធិ ហើយ ឈ្មោះ សាធា

ខ៖  កូនទី4ប្រុសឈ្មោះ ស៊ុន ឡុងឌី

ក៖  បាទ៎!បងចុះពៅគេ?

ខ៖  កូនទី5ពៅគេឈ្មោះ ស៊ុន បណ្ឌិត

ក៖  ចុះបងមានចងចាំអនុស្សាវរីយ៍អីជាមួយគាត់ កាលពីបងនៅក្មេងៗដែរទេ?

ខ៖  អនុស្សាវរីយ៍?

ក៖  ដូចថាលក្ខណះលេងឡើកបាយឡ រីលេងបិទពួនអីចឹងបង?

ខ៖  ដូចជាមិនសូវបានលេងឡើកបាយឡ រីមួយលេងបិទពួនអីផងនឹង
បងកាលពីដើមនៅក្មេង

ក៖  ចុះកាលបងពីនៅក្មេងប៉ុននោះបងធ្លាប់បានលេងអីទៅ?

ខ៖  ធម្មតាបងប្អូនមិនដែរបានលេង
ដូចជាភ្លេចអស់ហើយអូនកាលពីជំនាន់មុនមកឥឡូវនឹងណាស់

ក៖  ធ្លាប់ទៅស្រែអីទេបង?

ខ៖  ធ្លាប់ទៅស្រែទៅលេង ទៅច្រូតអីចឹងទៅលក្ខណះធ្វើជុំគ្នាចឹងទៅណាស់
ហើយបងនៅក្មេងៗជុំគ្នាចឹង ម្ដាយរបស់បងធ្វើស្រែគាត់មិនសូវបានចូលជាមួយគេទេ
គាត់ធ្វើតែជាមួយកូនចៅគាត់នឹង

ក៖  អ៊ូ!ចឹងហោសបង?

ខ៖  ចុះកូនចៅគាត់មាន3នាក់សុទ្ធតែស្រីទាំង3នាក់នោះ

ក៖  បាទបងបាទ?

ខ៖ ធ្វើចឹងមួយថ្ងៃហើយស្រែមួយៗ

ក៖ បាទបង ចុះបងចូលចិត្តលេងអីគេជាមួយបងប្អូនរបស់បងកាលពីនៅក្មេងដែរបង?

ខ៖ បងចូលចិត្តលេងឡឹកបាយឡ មានដាំបាយអី មានកូនក្រមុំមានផ្ទះតូចៗអីចឹង

ក៖ មិញខ្ញុំសួរបងបងថាអត់មានលេងទេដល់សួរម្ដងទៀតបងថាមានលេង?

ខ៖ សួរមិញវាភ្លេចតែបងលេងចឹង លេងតែបាយឡឹកបាយឡនឹង
នឹងលេងធ្វើដាំបាយអីចឹងទៅណាស់ នឹងលេងបេះបន្លែអីយកមកស្លចឹងទៅ

ក៖ នឹងលេងធ្វើកូនក្រមុំ កូនកំលោះអីចឹងទៅ?

ខ៖ ចាំ!លេងកូនក្រមុំកូនកំលោះហៃអីចឹងទៅ នឹងមានហៃកូនក្រមុំនឹងហៃកូនកំលោះទៀត

ក៖ ប៉ុន្តែលេងជាមួយបងប្អូនរបស់បងនឹង?

ខ៖ ចាំ!លេងតែជាមួយបងប្អូននឹង

ក៖ ចុះប្អូនរបស់បងគាត់សព្វថ្ងៃនឹងគាត់នៅណាដែរបង?

ខ៖ ប្អូនរបស់បងនឹងនេះប្អូនរបស់បងមួយ ប្អូនបងមួយទៀតនៅប្រទេសរុស្ស៊ី

ក៖ អូ៎!នៅបានឆ្ងាយផងនឹង?

ខ៖ ចាំ!ហើយប្អូនប្រុសមួយទៀតនៅប្រទេសកូនរ៉េ

ក៖ នៅឆ្ងាយៗដែរនឹង?

ខ៖ ហើយប្អូនពៅមួយទៀតនឹងនៅខេត្តកំពង់ធំ

ក៖ អូ៎!ខ្ញុំស្មានតែមួយទៀតនៅអាមេរិច?

ខ៖ អត់ទេនៅកំពង់ធំនឹង

ក៖ ប៉ុន្តែពួកគាត់បានប្ដីនៅណុងមែនបង?

ខ៖ ចាំ! ប៉ុន្តែបើនៅកូនរ៉េវិញទៅធ្វើការនៅកូរ៉េទេ

ក៖ អូ៎!ប្អូនបងនៅកូរ៉េធ្វើការទេ?

ខ៖  ចាំ!ធ្វើការទេ

ក៖  ចុះប្អូនរបស់បងធ្វើការងារអីគេខ្លះដែរបង
ដូចជាប្អូនបងនៅរូស្ស៊ីគាត់ធ្វើអីគេដែរទៅបង?

ខ៖  ប្អូនបងនៅរូស្ស៊ីនឹងគាត់កាត់ដេរខោអាវ

ក៖  អូ៎!ចឹងបានលុយច្រើនហើយចឹង?

ខ៖  មិនសូវបានប៉ុន្មានទេអូន
ដោយសារតែយើងនៅតែផ្ទះមើលកូនហើយមានកូនដល់ទៅ2នាក់នោះ
ចឹងរកមិនសូវបានដោយសារតែកូនៗនឹងតូចហោស

ក៖  ប៉ុន្តែគាត់បានប្តីជាជនជាតិរូស្ស៊ីហោសបង?

ខ៖  បានប្តីជាជនជាតិខ្មែរយើងតើ ប៉ុន្តែគេទៅនៅប្រទេសរូស្ស៊ីនឹង

ក៖  អូ៎!ចឹងគាត់អនិកជនហោសបង?

ខ៖  ចាំ!នឹងហើយ គាត់ពីមុនគាត់ទៅរៀននៅប្រទេសរូស្ស៊ី
ដល់ពេលនឹងទៅមិនដឹងជាយ៉ាងម៉េចទេគាត់ ក៏ទៅនៅនឹងរហូតទៅ

ក៖  ហើយគាត់ក៏បានមកយកប្រពន្ធនៅនឹង?

ខ៖  ហើយប្រពន្ធគេទៅធ្វើការនៅណុងចឹងបានបានជួបគ្នាចឹងទៅ

ក៖  អូ៎!ប្អូនរបស់បងគាត់ទៅធ្វើការនៅណុងហោសបង?

ខ៖  ចាំ!វាចឹងតើ!ពេលដែរទៅជួបគ្នានឹងក៏បានស្រលាញ់ទាក់ទងគ្នាចឹងទៅណាស់

ក៖  បាទល្អបង?

ខ៖  ឥឡូវនឹងគាត់បានកូន2នាក់ហើយនឹង

ក៖  ប៉ុន្តែប្អូនរបស់បងនៅកូរ៉េនឹងគាត់ធ្វើអីគេដែរបង?

ខ៖  ប្អូនរបស់បងនៅកូរ៉េគាត់ធ្វើការរោងចក្រនៅកូរ៉េ

ក៖  ប៉ុន្តែប្រុសមែនទេបង?

ខ៖  ចា៎!ប្រុសតើ!

ក៖  ប៉ុន្តែប្អូនបងនៅកំពង់ធំគាត់ធ្វើអីគេដែរបង?

ខ៖  ប្អូនបងនៅកំពង់ធំនឹងរាល់ថ្ងៃគាត់រកស៊ី ដើរទិញស្រូវអីចឹងទៅ

ក៖  បាទបង ចុះឪពុករបស់បងគាត់មានឈ្មោះអីគេដែរបង?

ខ៖  ឪពុករបស់បងគាត់មានឈ្មោះ ងួន ស៊ីម

ក៖  ចុះគាត់អាយុប៉ុន្មានដែរបង?

ខ៖  ឪពុករបស់ខ្ញុំនឹងដូចជាអាយុហេ៎! អាយុប៉ុន្មានទេនេះអាយុ69ឆ្នាំនឹង

ក៖  អូ៎!អាយុ69ឆ្នាំនឹងហោសបង?

ខ៖  ចា៎!ប៉ុណ្ណឹង

ក៖  ប៉ុន្តែបងមានដឹងថាគាត់កើតនៅថ្ងៃខែឆ្នាំណាទេបង?

ខ៖  ហេ៎!បងមិនសូវដឹងថាគាត់កើតនៅថ្ងៃខែឆ្នាំណាដែរនឹង ដឹងតែគាត់កើតឆ្នាំខាល

ក៖  អូ៎!ចឹងហោសបង?

ខ៖  នឹងហើយថ្ងៃខែឆ្នាំគាត់បងមិនដឹងទេគ្រាន់តែដឹងថាគាត់កើតនៅឆ្នាំខាល

ក៖  អូ៎!គាត់កើតឆ្នាំខាល ចុះគាត់កើតនៅណាបងមានដឹងទេបង?

ខ៖  គាត់កើតនៅណាក៏បងមិនដឹងដែរអូនអើយ បើមិនដឹងថាគាត់នៅណាផង ដឹងថាពីដើមនឹងម៉ែគាត់ នឹងនៅទួលព្រិចនោះ

ក៖  អូ៎!ចឹងហោសបង?

ខ៖  ដូចជានៅទំពាំងឬស្សីនឹង យាយរបស់ខ្ញុំនៅដុកអង្រែ ប៉ុន្តែឪពុករបស់ខ្ញុំនឹងនៅទំពាំងឬស្សីនឹង

ក៖  ចឹងសំរាប់ឪពុករបស់បងគាត់កើតនៅឆ្នាំ1949បង?

ខ៖  ឪពុកបងហោស?

កៈ  បាទបង ចុះម្ដាយរបស់បងឈ្មោះអីគេដែរបង?

ខៈ  ម្ដាយរបស់បងគាត់ឈ្មោះយ៉ុក ផុង

កៈ  ចុះគាត់អាយុប៉ុន្មានដែរបង?

ខៈ  គាត់អាយុ64ឆ្នាំហើយគាត់កើតឆ្នាំរកអូនដូចជាហុនប៉ុន្មាននេះ

កៈ  គាត់បងតាហោសបង?

ខៈ  គាត់ប្អូនពុកទេហី

កៈ  គាត់ប្អូនគ្នាប៉ុន្មានឆ្នាំដែរបង?

ខៈ  គាត់ប្អូនគ្នាប៉ុន្មានឆ្នាំទេនេះ ម៉ែរបស់ខ្ញុំអាយុ62ឆ្នាំហើយចឹងណោះ

កៈ  គាត់អាយុ62ឆ្នាំចឹង ចឹងគាត់កើតនៅឆ្នាំណាបងមានដឹងទេ?

ខៈ  អត់ដឹងទេ និយាយពីប្រវត្តិម៉ែឪគាត់កើតនៅឆ្នាំណាបងមិនដឹងទេ

កៈ  អូ៎!ចឹងហោសបង?

ខៈ  នឹងហើយបើរកអាយុ51ឆ្នាំ បើមមែអាយុ52ឆ្នាំ គាត់កើតនៅឆ្នាំ1951

កៈ  នៅឆ្នាំ1951
ប៉ុន្តែនៅក្នុងនេះគេដាក់ឆ្នាំ1956សំរាប់ខ្ញុំចែកណាស់បើគាត់អាយុ61ណាស់បង
គាត់មិញនឹងគាត់អាយុ61ឆ្នាំហីបង?

ខៈ  គាត់អាយុ62ឆ្នាំ

កៈ  ចឹងគាត់កើតនៅឆ្នាំ1956បង?

ខៈ  អូ៎!ចឹងអានឹងគេចែកដឹង

កៈ  ចុះម្ដាយរបស់បងគាត់កើតនៅណាដែរបង?

ខៈ  ម្ដាយរបស់បងគាត់កើតនៅនឹងនៅភូមិដក់ពរនឹង

កៈ  អូ៎!បាទបង ចុះឪពុករបស់បងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមបង?

ខ៖  កាលពីដើមមកនិយាយទៅកាលពីគាត់ចេញពីជំនាន់ពលពតណាស់

ក៖  បាទបងគាត់ធ្វើអីគេ?

ខ៖  ឪពុករបស់ខ្ញុំគាត់ជាអ្នកលក់ប៉េងប៉ោង គាត់លក់ប៉េងប៉ោងនៅតាមវត្តអីចឹងទៅណាស់

ក៖  អូ!បាទបងគាត់ធ្វើចឹង?

ខ៖  និយាយទៅអោយតែមានបុណ្យគាត់ទៅលក់ប៉េងប៉ោងនៅតាមវត្តហើយនឹង
ដោយសារតែខ្ញុំកូនទី1 ចឹងខ្ញុំឧស្សាហ៍ទៅតាមគាត់ណាស់

ក៖  អូ!បាទចឹងហោសបង?

ខ៖  ទៅលក់ចឹងកាលពីជំនាន់ណុងយើងជិះកងចឹងទៅណាស់អូន

ក៖  ចុះលក់ប៉េងប៉ោងនៅណាដែរបង?

ខ៖  ទៅលក់ប៉េងប៉ោងតាមវត្ត នឹងទៅតាមភូមិអីចឹងទៅ

ក៖  ប៉ុន្តែនៅនឹង?

ខ៖  នៅនឹងប៉ុន្តែគ្រាន់តែយើងដើរលក់ឆ្ងាយ
ប៉ុន្តែយើងទៅទិញប៉េងប៉ោងនឹងនៅភ្នំពេញហោស

ក៖  អូ!ទៅទិញបានឆ្ងាយផងនឹង?

ខ៖  ទៅទិញនៅភ្នំពេញ នៅអូរឬស្សីនឹងណាស់

ក៖  ទាល់តែទៅទិញនៅណុងបានវាថូរថ្លៃមែនទេបង?

ខ៖  ចាំ!នឹងហើយនៅស្រុកនឹងគ្មានប៉េងប៉ោងទេ
ហើយបើបងគ្មានអីធ្វើទេបងទៅជួយលក់គាត់ហើយនឹង
នឹងទៅចឹងទៅកាលពីដើមកំសត់ហាសណាស់អូនចឹងខ្ញុំយំតាម
ហើយម៉ែឪឈ្លោះគ្នាចឹងទៅក៏ចែក កូនមួយម្នាក់ ដល់ពេលចឹងខ្ញុំតាមឪពុករបស់ខ្ញុំ
ហើយពេលចឹងទៅខ្ញុំបានស្រែកទឹកហើយគ្មានអីហូបចឹង

ក៖  ចុះយ៉ាងម៉េចទៅចឹងបង?

ខ៖ ដល់ពេលចឹងខ្ញុំស្រែកទឹកហើយគ្មានអីហូបនឹងខ្ញុំប្រាប់គាត់ថាពុកខ្ញុំស្រែកទឹកណាស់ហើយគាត់បានទៅយកទឹកអាគេឈ្ងួសទឹកកកហោស

ក៖ អូ!អាទឹកកកគេឈ្ងួសនឹងហោសបង?

ខ៖ នឹងហើយទឹកកកដែរគេដាក់ក្នុងធុងនឹង ហើយគេមិនលាងទឹកកកដើម្បីយកមកប្រើ

ក៖ អូ!គាត់យកទឹកដែរគេសំរាប់លាងទឹកកកនឹងហោសបង?

ខ៖ ហើយគេយកអាទឹកកកដែរមានសិទ្ធិតែអង្កាមនឹងណាស់ ហើយគាត់បានយកទឹកអង្កាមនឹងមក អោយខ្ញុំផឹកនឹង

ក៖ អូ!ចឹងហោសបង?

ខ៖ អូនចង់ដឹងប្រវត្តិវាហោស ម៉ែឪវាលែងគ្នាគាត់ឈ្លោះគ្នាមានកូន2នាក់ហើយចែកគ្នាហើយដល់ពេល ចឹងគេមិនបើកមហោស្រពនឹង ហើយគាត់នឹងកាលពីជំនាន់ឆ្នាំ1979នឹងគាត់គុមន្ទីសចំតែម្ដងនឹងអូន គេមិនលេងរបាំ ហើយគាត់មានកងមួយកងទូកប្រុស ហើយបងកងអោយកូនដេកនៅក្នុងកងនឹង

ក៖ អូ!ចឹងហោសបង?

ខ៖ នឹងហើយចំពេលដែរគេឈ្ងួសទឹកកក វាយំទាទឹកកកផឹកនឹងប៉ុននេះ

ក៖ ប៉ុននឹងប្រហែលជាប៉ុន្មានឆ្នាំដែរបង?

ខ៖ មានអាយុ2ឆ្នាំនឹងពេលនឹងខ្ញុំដឹងហោស ចុះទៅសុំកាលពីដើមគេដែរអោយយើងផឹកហោស អត់មានទឹកណាអោយផឹកទេ

ក៖ ចុះយើងធ្វើម៉េចទៅ?

ខ៖ ហើយដល់ពេលចឹងទៅគាត់ក៏ទៅដងទឹកធុងគេដែរសុទ្ធតែអង្កាមអោយមកផឹកនឹងដងមួយវែកៗ អោយផឹកហើយខ្ញុំជាអ្នកឈរមើលខ្ញុំបានដឹងចឹងទៅ

ក៖ ចឹងមានអីកើតឡើងទៅបង?

ខ៖  គ្មានអីទេ ខ្ញុំមកប្រាប់យាយៗនៅខាងនេះហើយវាក៏យំអញ់ថាហោមីមុខងាប់
គេនៅនោះសោះឯងមក យំអីដែរនឹងអាណិតប្រវត្តដល់កំសត់នឹង
នឹងកំណើតវាវាកំសត់ដែរនឹង ចុះបើនៅនេះគេលែងគ្នាហើយ
យកគ្នាមកចងអង្រឹងនៅនឹងកងនឹង

ក៖  និយាយរឿងកំសត់ទៅជារឿងកំប្លែងវិញ?

ខ៖  ទៅជាកំប្លែងវិញហើយនេះនៅតូចនឹងនៅខាងម៉ែ

ក៖  អុំ!មានរឿងកំប្លែងច្រើនបង?

ខ៖  អុំ!មានកំប្លែងដែរនឹង

ក៖  ចុះបងមានចងចាំថាកាលពីបងនៅជាមួយម្ដាយឪពុករបស់បងនឹង
តើបងធ្លាប់មានសាច់រឿងអីជា មួយគាត់ដែរទេបង?

ខ៖  រឿងម៉ែឪនឹងមិនចេះអត់ទេអូន រឿងប្ដីប្រពន្ធក្រុមគ្រួសាររបស់យើងនឹងអាជូក៏មាន
អាផ្អែមក៏មានដែរ អូន

ក៖  អាចត់ក៏មានដែរហោសបង?

ខ៖  អាល្វីក៏មានដែរអូនមានច្រើនណាស់

ក៖  ប៉ុន្តែបងអាចរៀបរាប់ខ្លះដែរបានទេបង?

ខ៖  ចាំ!នៅក្នុងក្រុមគ្រួសារមិនដែរចេះអត់ទេនឹង

ក៖  កាលពីបងនៅជាមួយពួកគាត់បងធ្លាប់មានអនុស្សាវរីយ៍អីចឹង
បងធ្លាប់មានធ្វើអីគេខ្លះជាមួយពួកគាត់ដែរចឹងណាស់បង ធ្លាប់ទៅណាអីជាមួយគ្នា
ធ្លាប់លេងអីជាមួយគ្នាចឹងទៅណាស់បង?

ខ៖  ធ្លាប់ទៅវត្តធ្វើបុណ្យជាមួយគាតចឹងទៅ
ខ្សែខាងម៉ែរបស់យើងដូចថាមិនសូវបានទៅដើរលេងនៅ
ណាទេគ្រាន់តែថានាំកូនចៅទៅធ្វើបុណ្យ
ទិញឥវ៉ាន់ទៅយកទៅប្រគេនលោកចឹងទៅណាស់

ក៖  អុំ!បាទបង?

ខ៖ លក្ខណៈវេចង្ហាន់ចឹងទៅប្រកេនជួបលោកចឹងទៅណាស់

ក៖ ចុះឪពុកម្ដាយរបស់បងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងៗទៅបងដែរទេ?

ខ៖ គាត់ធ្លាប់ប្រាប់ឪពុករបស់ខ្ញុំគាត់មិនដែរប្រាប់ប្រវត្តិគាត់ទេ ប៉ុន្តែម្ដាយរបស់ខ្ញុំនឹងគាត់ធ្លាប់ប្រាប់

ក៖ គាត់ធ្លាប់ប្រាប់ថាយ៉ាងម៉េចទៅបង?

ខ៖ ម៉ែខ្ញុំគាត់ធ្លាប់ប្រាប់ថាកាលពីនៅតូចគាត់មិនដែរបានទៅរៀនទេ ម៉ែឪគាត់មិនដែរអោយគាត់ទៅរៀន ទេណាស់

ក៖ អូ៎!ចឹងហោសបង?

ខ៖ គាត់រៀនបានថ្នាក់ទី11ទេនឹង ដល់ពេលដែរកាត់រៀនបានថ្នាក់ទី12នឹងអោយគាត់មើលតែកូនអោយ គេនឹងអោយមើលកូនបងៗនឹងចុះយាយរបស់ខ្ញុំនឹងមានកូនដល់ទៅ12នាក់ណាស់

ក៖ អូ៎!ច្រើនដែរណាបង មួយឡូហើយនឹង?

ខ៖ នឹងហើយកូន12នាក់ហើយកូនបងៗគាត់នឹងអត់មាននរណាគេមើលចឹងទៅអោយគាត់ទៅមើល អោយគេចឹងទៅណាស់ហើយគាត់មិនបានទៅរៀនទេ

ក៖ ចឹងគាត់ក៏ឈប់រៀនទៅហោសបង?

ខ៖ នឹងហើយគាត់ក៏ខឹងម៉ែមិនអោយទៅរៀនទៅអោយគាត់ទៅមើលតែកូនគេនឹងខ្ញុំដឹងតែចឹងនឹង

ក៖ បាទចឹងសំរាប់យាយតាខាងឪពុកនឹងបងស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ យាយតាខាងឪពុកនឹងស្គាល់តើ!

ក៖ គាត់មានឈ្មោះអីគេដែរបង?

ខ៖  តាឈ្មោះតាងួន អត់ស្គាល់ត្រកូលគាត់ទេ

ក៖  ចុះយាយវិញបងឈ្មោះអីគេដែរបង?

ខ៖  យាយឈ្មោះយាយផន

ក៖  ចុះយាយតាខាងម្ដាយវិញ?

ខ៖  បើតាខាងម៉ែឈ្មោះតាភួង យាយមន

ក៖  ប៉ុន្ដែគាត់កើតនៅណាបងមានដឹងទេ ទាំងយាយតាខាងម្ដាយ នឹងខាងឪពុកចឹងណាស់

ខ៖  យាយតាខាងឪពុកដឹងតែតាកើតនៅភូមិរំដួល យាយកើតនៅដុកសង្វៃ ប៉ុន្ដែគាត់ពីមុនមិនដឹងទេណាស់

ក៖  នឹងខាងឪពុក?

ខ៖  នឹងខាងឪពុក

ក៖  ចុះខាងម្ដាយវិញបង?

ខ៖  ខាងម្ដាយគាត់នៅដក់ពរ មិនដឹងថាគាត់នៅណាទេអូយាយនៅកកៀត

ក៖  កកៀតនៅណាដែរបង?

ខ៖  កកៀតនៅនឹង ហើយតានៅភូមិដក់ពរ

ក៖  អូ៎!នៅភូមិដក់ពរនៅនឹងហោសបង?

ខ៖  ចា៎!នៅនឹងឯង

ក៖  បងមកនៅខេត្តនឹងយូរនៅបង?

ខ៖  បងមកនៅនឹងយូរដែរហើយតាំងពីបងដឹងក្ដីមកបងនៅនឹងរហូតនឹង

ក៖  ចឹងបងកើតមកនៅនឹងរហូតអស់ប្រហែលជា30ឆ្នាំជាងហើយណាបង?

ខ៖  ចា៎!នឹងហើយជាង38ឆ្នាំហើយនឹង

កៈ  អស់39ឆ្នាំ
មិញដូចជាមានបងប្អូនបងមួយចំនួនដូចជាទៅនៅប្រទេសក្រៅដែរមែនទេបង?

ខៈ  ចាំ!មានតើ!

កៈ  ចុះមានតែនៅកូរ៉េ នឹងនៅរូស្ស៊ីទេ ចុះមាននៅណាផ្សេងទៀតអត់បង?

ខៈ  មានតែនៅកំពង់ធំ

កៈ  អត់ទេចង់និយាយថានៅក្រៅប្រទេសណាស់?

ខៈ  អត់មានទេអូនមានតែ2នាក់នឹងទេ

កៈ  ចុះនៅថៃ នៅវៀតណាមអីអត់មានទេណបង?

ខៈ  ចាំ!អត់មានទេនឹង

កៈ  បងប្អូនកូនក្មួយអីក៏អត់មានដែរ?

ខៈ  មានតែបងប្អូនជីដូនមួយ

កៈ  ចុះជីដូនមួយនៅណាដែរបង?

ខៈ  គេនៅថៃ

កៈ  គាត់ធ្វើអីគេនៅថៃដែរបង?

ខៈ  គេជាអ្នករកស៊ីចំណាកស្រុកទៅថៃ

កៈ  អូ៎! ដូចតែប្អូនរបស់បងគាត់ទៅធ្វើការនៅកូរ៉េដែរនឹងហោសបង?

ខៈ  ចាំ!វាចឹង

កៈ  ចុះសំរាប់ស្វាមីរបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ  ស្វាមីរបស់បងគាត់ឈ្មោះស៊ីន ប៉ូរ៉ាត់

កៈ  ចុះបងមានចងចាំថ្ងៃខែដែរបងរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីរបស់បងទេ
នៅថ្ងៃខែឆ្នាំណាដែរទេ?

ខ៖ បងរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី17 ខែ3 ឆ្នាំ1998

ក៖ ចុះនៅពេលដែរបងរៀបអាពាហ៍ពិពាហ៍នឹងគិតថាបងជាអ្នករៀបចំដោយចិត្តឯង រឺឪពុកម្តាយរបស់ បងជាអ្នករៀបអោយដែរ?

ខ៖ ជំនាន់ណុងម្តាយឪពុកជាអ្នករៀបចំអោយអូនអត់ដែរស្រលាញ់គ្នាដោយចិត្តឯងទេ មិនដែរស្គាល់មុខគ្នាទៀតនឹងណាស់

ក៖ អត់ដូចក្មេងសម័យឥឡូវនឹងទេណបង?

ខ៖ អត់ដែរបានទាក់ទងនិយាយគ្នាមួយម៉ាត់នឹងក៏អត់មានដែរ

ក៖ ចឹងអត់ដែរនិយាយជាមួយគ្នាទេ?

ខ៖ អត់ដែររាក់ទាក់គ្នាសូម្បីតែនិយាយរកគ្នាឃើញគ្នាការតែម្តងទៅ

ក៖ ក្មេងសម័យឥឡូវនឹងទាល់ទាក់ទងគ្នាបានកន្លះឆ្នាំ រឺមួយឆ្នាំសិនបានបាន

ខ៖ នឹងហើយវាចឹងក្មេងសម័យឥឡូវនឹងទាល់តែស្គាល់ចិត្តថ្លើម ហើយដឹកគ្នាដើរលេងសិនបានការណាស់ ពីមុនអត់ចឹងទេអូនអើយ

ក៖ ចុះនៅពេលដែរប្តីបងចូលស្តីដណ្តឹងបងនឹងដូចជាមានលក្ខណះថាជាថ្លៃទឹកដោះទេបង?

ខ៖ មានតើ ជំនាន់ណុងថ្លៃទឹកដោះ5ជីណាស់

ក៖ បងបាន5ជី?

ខ៖ ចា៎!បាន5ជីប៉ុន្តែយើងហូបទាំងអស់គ្នាដែរនឹងលក្ខណះថាចេញពាក់កណ្តាលម្នាក់ទេនឹង ហើយថ្លៃទឹកដោះបានតែ5ជីទេ

ក៖ បាន5ជីថ្លៃទេជំនាន់ណុងបង?

ខ៖ អ៊ូ!គ្មានថ្លៃអីទេអូនអើយ5ជីនឹងអូន ចំណែកអញ់បាន70ម៉ឺន ដូចតែគ្នាទេនឹង

ក៖ អ៊ូ!5ជីនឹង70ម៉ឺនដូចតែគ្នានឹងហោសបង?

ខ៖ នឹងហើយដូចតែគ្នាទេនឹង

ក៖ ចុះបងអាចប្រាប់ពីប្រវត្តិស្នេហាបងតិចបានទេបង
ដូចជាបងបានជួបគ្នាជាមួយប្តីបងនៅពេលណា ហើយហេតុអីបានបងជួបគ្នាចឹង?

ខ៖ អត់ដែរបានជួបគ្នាទេនឹង អត់ដែរបានជួបតែម្តងនឹង

ក៖ អូ៎!ចឹងហោសបង?

ខ៖ និយាយពីប្រវត្តិស្នេហាចប់បាត់ហើយអូនអើយ អត់ដែរឃើញគ្នាទេនឹង

ក៖ អត់ដែរឃើញគ្នាពីមុនតែម្តងហោសបង?

ខ៖ អត់ទេនឹងឃើញគ្នាចេះតែស្គាល់ហើយប៉ុន្តែអត់ដឹងថាកូននរណាអីនរណាទេនឹង

ក៖ អូ៎!ចឹងមានន័យថាខាងគេចូលសណ្តឹងយើងយកតែម្តងនឹងហោសបង?

ខ៖ នឹងហើយខាងគេចូលមកនឹង សូម្បីតែប្តីនឹងក៏មិនដែរឃើញដែរនឹង

ក៖ អូ៎!បាទចុះបងធ្លាប់រៀនខ្មែរដែរទេ?

ខ៖ បងធ្លាប់ដែរនឹង

ក៖ បងរៀនបានថ្នាក់ទីប៉ុន្មានដែរបង?

ខ៖ បងរៀនបានថ្នាក់ទី8ដែរ

ក៖ ចុះកាលពីបងរៀននឹងបងរៀននៅណាដែរបង?

ខ៖ កាលពីបងរៀននឹងបងរៀននៅអង្គព្រៃហោស
ហើយបន្ទាប់មកបងរៀននៅសាលាទួលស្វាយរដ្ឋ

ក៖ ឈ្មោះសាលាចឹងតែម្តងហោសបង?

ខ៖ ចា៎!ឈ្មោះសាលាចឹង កាលណុងរៀននៅទួលស្វាយរដ្ឋថ្នាក់ទី5
បន្ទាប់មកយើងទៅរៀននៅ អនុវិទ្យាល័យចំបក

ក៖ អូ៎!នៅចាំបកយើងនឹងហោសបង?

ខ៖ នឹងកាលពីថ្នាក់ទី8នឹង

កៈ ចុះបងមានចេះភាសាអីក្រៅពីភាសាខ្មែរទេបង?

ខៈ អត់ទេអូនអើយបងមិនចេះអីទេបងចេះតែភាសាខ្មែរនឹង

កៈ វៀតណាម ថៃ កូនរ៉េក៏អត់ចេះដែរ?

ខៈ អត់ចេះទេអូនអើយ អត់លើងនឹង

កៈ ចុះបងធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាទេ លក្ខណៈមិត្តភក្តិស្និទ្ធស្នាលណាស់បង?

ខៈ បងមានមិត្តភក្តិតើអូន

កៈ ចុះបងអាចប្រាប់ឈ្មោះមួយចំនួនដែរបងបានចាំទេ?

ខៈ មិត្តភក្តិបងមិនដឹងណាណីទេ គិតទៅច្រើនណាស់

កៈ អត់ទេបង បងគិតថារៀបរាប់តែមិត្តភក្តិមួយចំនួនដែរបងគិតថាជិតស្និទ្ធិនឹងបង?

ខៈ បើជិតស្និទ្ធិតែម្តងនឹងមានតែ3នាក់ទេនឹង

កៈ ចឹងមានតែ3នាក់ទេ?

ខៈ ដែរបងទៅណា មកណាតែជាមួយគ្នានឹង

កៈ ប៉ុន្តែមានឈ្មោះអីគេខ្លះដែរបង?

ខៈ មានឈ្មោះភែ ចាន់ភឿន សួន ហើយនឹងសួង សុខា មានតែបីនាក់នឹង

កៈ បាទចឹងមានជាអនុស្សាវរីយ៍អីកាលពីបងនៅក្មេងៗជាមួយពួកគាត់ណាស់ ធ្លាប់ធ្វើអីគេខ្លះជាមួយគ្នាចឹងណាស់បង?

ខៈ ធ្លាប់លេងបាយឡឹកបាយឡជាមួយគ្នាចឹងទៅ ទៅមុជទឹកអីជាមួយគ្នា នឹងទៅស្រែអីជាមួយគ្នាចឹងទៅណាស់

កៈ អូ៎!មានច្រើនដែរហោសបង?

ខៈ នឹងហើយធ្លាប់ទៅកាប់អូសអីជាមួយគ្នាចឹងទៅ នឹងមិត្តភក្តិតែបីនាក់នឹង

កៈ ចុះពេលដែររៀនធ្លាប់ធ្វើអីជាមួយគ្នាដែរទៅបង?

ខ៖ កាលពីទៅរៀនយើងទៅរៀនជាមួយគ្នាចឹងទៅណាស់ បើដើរដើរតាំងអស់គ្នា បើមានកងជិះនឹងជិះ ទាំងអស់គ្នាចឹងទៅ

ក៖ ចឹងមានន័យធ្វើអីធ្វើទាំងអស់គ្នា?

ខ៖ នឹងហើយបើថាអត់កងអត់ទាំងអស់គ្នាចឹង

ក៖ អូ៎!នឹងអនុស្សាវរីយ៍មិត្តភក្តិរបស់បងណាបង?

ខ៖ នឹងហើយមានចឹង

ក៖
ចុះបងគិតថាធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់បងតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ បងធ្លាប់ធ្វើការរោងចក្រ ក្រៅពីនឹងបងមិនធ្លាប់បានធ្វើអីទេអូន

ក៖ ចឹងធ្វើការតែរោងចក្រទេណាបង?

ខ៖
ចា៎!បងធ្វើការរោងចក្របានប៉ុន្មានឆ្នាំហើយបងមានប្តីនឹងមានកូនចឹងទៅបងក៏ឈប់ទៅ

ក៖ ចុះបងធ្លាប់ទៅធ្វើការនៅវាលស្រែដែរទេបង ដូចជាលក្ខណៈធ្វើស្រែចំការណាស់បង?

ខ៖ បងធ្លាប់ធ្វើស្រែចំការ

ក៖ លក្ខណៈថាធ្វើយ៉ាងម៉េចដែរបង លក្ខណៈថាទៅដក ស្ទូងអីចឹងផ្សេងៗចឹងមែនបង?

ខ៖ ដក ស្ទូង ច្រូត ការងារនឹងពីមុនមកយើងរកអូស

ក៖ អូ៎!បងរកអូសដែរហោសបង?

ខ៖ ចា៎!យើងខែប្រាំងចឹងទៅយើងទៅរកអូសរកនៅអូរនៅលិចហោស យើងទៅរកអូសពីដើមនឹងមិនដូច ឥឡូវនឹងទេ

ក៖
ចុះបងគិតថាជីវិតរបស់បងតាំងពីក្មេងរហូតមកដល់ពេលនេះមានការផ្លាស់ប្តូរអីគេខ្លះដែរបង?

ខ៖  ពីដើមនឹងឥឡូវនឹងមានការផ្លាស់ប្តូរចឹងយើងខុសគ្នាណាអូន

ក៖  ខុសគ្នាយ៉ាងម៉េចទៅបង?

ខ៖  ពីដើមនឹងរកមុខខ្វះក្រោយ
ដូចថាលុយកាក់អីក៏យើងមិនសូវមានសំបូរចាយដូចឥឡូវនឹងដែរ
ហើយដល់ពេលឥឡូវនឹងយើងមានហូប មានចុកស្រួលចឹងទៅ
ហើយលុយកាក់អីក៏យើងមិនសូវជាមាន ច្រើនដែរណាអូន

ក៖  បាទត្រូវហើយបង?

ខ៖
ដូចថាពីដើមនឹងលុយកាក់យើងមានតែ200រៀលនឹងច្រើនហើយណាអូនលុយទៅរៀននឹងអូន

ក៖  បាទនឹងហើយបង?

ខ៖  ហើយកូនចៅឥឡូវនឹងកូនចៅនឹងលុយរាប់ពាន់ណា
ហើយខោអាវវិញសឹងតែថាមួយឆ្នាំមិនទាន់ បានទិញមួយកំភ្លេរផងនឹង
ហើយយើងពីដើមនឹងស្លៀកតែខោអាវជជុះ

ក៖  អ៊ូ!វាមិនសូវមានខោអាវមែនបង?

ខ៖  នឹងហើយខោអាវជជុំរាថោក

ក៖  ចុះបងគិតថាបងចូលចិត្តពិសារម្ហូបអីគេដែរបងឥឡូវនឹងណាស់?

ខ៖  និយាយពីម្ហូបហោស?

ក៖  បងចូលចិត្តណាស់ម្ហូបអីដែរបងចូលចិត្តដែរ?

ខ៖  បងចូលចិត្តហូបសំលម្ជូរ

ក៖  អ៊ូ!ចូលចិត្តម្ជូរ ចុះមានស្អីទៀតទេដែរបងចូលចិត្តដែរដូចជាស្ងោរ ឆា ចៀននឹង?

ខ៖  នឹងធម្មតាទេនឹង
ដូចថាជាធម្មតាទេដូចថាម្ហូបណាដែររៀងប្លែកតិចចឹងទៅយើងក៏ហូបចឹងទៅណាស់

ប៉ុន្តែអោយម្ហូបដែរចូលចិត្តតែម្តងនឹងដូចជាមិនមានអីដែរចូលចិត្តទេនឹង

ក៖ ចុះកាលពីនៅក្មេងបងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេដែរបងដូចជាចោលឈូង ទាញព្រាត លាក់កន្សែង ?

ខ៖ បងចូលចិត្តលេងបោះអង្គុញ

ក៖ អូ!លេងបោះអង្គុញណាបង?

ខ៖ ចា៎!អ្វីដែរចូលចិត្ត

ក៖ ចុះបងចេះច្រៀងទេ?

ខ៖ អត់បងមិនចេះច្រៀងទេនឹង

ក៖ ចុះបងចូលចិត្តស្តាប់បទចំរៀងទេបង?

ខ៖ ចា៎!បងចូលចិត្តស្តាប់

ក៖ លក្ខណះបទសម័យ រឺមួយក៏បទបុរាណដែរបង?

ខ៖ លក្ខណះបទបុរាណនឹង

ក៖ ចុះបងចូលចិត្តមើលល្ខោន រឺយីកេរ្តិ៍អីទេបង?

ខ៖ កាលបងពីក្មេងនឹងបងចូលចិត្តស្តាប់បទយីកេរ្តិ៍តែឥឡូវនឹងបងមិនដែរបានស្តាប់ទេនឹង លក្ខណះយីកេរ្តិ៍រឿងទុំទាវ រឺផ្កាស្រពោនអីចឹងទៅ

ក៖ អូ!អ្វីដែរបងចូលចិត្តហោស?

ខ៖ ចា៎!ប៉ុន្តែវាយូរដែរហើយកាលពីមុននឹងចូលចិត្តស្តាប់នឹង

ក៖ បាទបងចឹង?

ខ៖ ចុះពីមុននឹងយើងគ្មានទូរស្សន៍មើលនេះ ចឹងយើងតាមដានតែវិទ្យុនឹង តាមដានរឿងក្នុងវិទ្យុអីចឹងទៅ អោយតែពេលថ្ងៃចឹងអូទៅយកវិទ្យុនឹងទៅផ្ទៀងស្តាប់ហើយនឹង

ក៖ ចុះមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់បងចេះលេងឧបករណ៍ភ្លេងដែរទេបង?

ខ៖

ក៖ លក្ខណៈភ្លេងខ្មែរ ភ្លេងពិនពាតអី រឺក៏ភ្លេងអាមេរិចអី រឺអកក្តុង ព្យាណូ រឺវីយូឡុងអីចឹងទៅបង?

ខ៖ នៅក្នុងស្រុកភូមិបងមានអ្នកលេងដែរតើ!

ក៖ ប៉ុន្តែសំរាប់បងប្អូនរបស់បងតែម្តងនឹង?

ខ៖ សំរាប់បងប្អូនរបស់បងអត់មានទេ

ក៖ ចឹងអត់មាននរណាគេចេះលេងទេណាបង?

ខ៖ ចា៎!អត់មានទេ

ក៖ បាទបង ចុះបងផ្ទះរបស់បងមានលក្ខណៈបែបណាដែរបង?

ខ៖ ផ្ទះរបស់បងមានលក្ខណៈថាឈើលើ ថ្មក្រោម

ក៖ ផ្ទះមួយនឹងមែនបង?

ខ៖ ផ្ទះបងមួយនោះទេ

ក៖ ចុះផ្ទះរបស់បងនរណាគេជាអ្នកធ្វើដែរ រឺក៏បងជួលគេជាអ្នកធ្វើដែរនឹងបង?

ខ៖ ពីដើមមកឪពុករបស់បងជាជាងផ្ទះដែរនឹង

ក៖ អូ៎!ចឹងមានន័យថាគាត់ចេះធ្វើហើយចឹងណោះ?

ខ៖ ចា៎!គាត់ចេះធ្វើជាជាងដែរនឹង

ក៖ ចុះនរណាគេជាអ្នកបង្រៀនអោយគាត់ចេះធ្វើដែរបង?

ខ៖ គាត់នឹងដូចជាបងមិនសូវដឹងទេនេះ ពីព្រោះការងារគាត់នឹងគាត់ចេះច្រើនណាស់

ក៖ ចឹងគាត់ចេះធ្វើច្រើនដែរចឹង?

ខ៖ ធ្វើផ្ទះក៏ចេះ ធ្វើធុងក៏គាត់ចេះដែរ នឹងជាជាងផ្ទះអីចឹងទៅណាស់

ក៖ ចុះបងគិតថាគេធ្វើនឹងគេប្រើឧបករណ៍អីគេខ្លះដែរសំរាប់សាងសងផ្ទះមួយនឹងដែរបង?

ខ៖ ផ្ទះរបស់បងនឹងមានឈើ មានរណា មានដែកឈូស

ក៖ នឹងមានស៊ីម៉ង់អីចឹងទៅ?

ខ៖ ចុះកាលពីជំនាន់ណុងយើងឈូសដោយដៃយើងនឹង

ក៖ ចុះស៊ីម៉ង់នឹងគេធ្វើពីស្អីគេដែរចឹងទៅណាបង?

ខ៖ ហើយមានស៊ីម៉ង់ មានឥដ្ឋ ខ្សាច់ នឹងដែកចឹងទៅយើងប្រើ នឹងឈើ គ្រឿងនឹង

ក៖ ចុះបងគិតថាជំនាញអីដែរបងគិតថាចេះស្ទាត់ជំនាញដែរបង?

ខ៖ ជំនាញបងនឹងមានចេះតែជំនាញដាំស្លនឹងហើយ

ក៖ អូ៎!ចឹងមានន័យថាចេះតែដាំស្លទៅបង?

ខ៖ នឹងហើយគ្មានអីចេះទៀតទេនឹង

ក៖ ចុះបងពូកែខាងដេរអីទេបង?

ខ៖ រឿងដេរប៉ាក់អីនឹងបងចេះដេរតើ

ក៖ ដោយសារតែបងធ្លាប់ធ្វើការងារជាងដេរណាបង?

ខ៖ ចា៎!ដោយសារតែខ្ញុំមិនធ្លាប់ទៅធ្វើអីទេនឹង

ក៖ ចុះឪពុកម្ដាយរបស់បងគាត់ធ្លាប់បង្រៀនពីជំនាញអីទៅបងទេ?

ខ៖ ម៉ែឪចឹង់និយាយបង្រៀនអីគេដែរ?

ក៖ លក្ខណះថាធ្វើកន្ទេល ធ្វើផ្ដៅ កក្កូរស្កត្នោត ធ្វើពន្លាក់អីទេបង?

ខ៖ គាត់មិនដែរបង្រៀនអោយកូនចេះធ្វើចឹងៗទេនឹង

ក៖ ចឹងគាត់បង្រៀនអោយចេះតែដាំស្លទេនឹង?

ខ៖ ចា៎!នឹងហើយ

ក៖ ចឹងចាប់ផ្ដើមចូលវគ្គនិយាយពីកាលលំបាករបស់បងវិញ
តាំងពីក្មេងរហូតមកដល់ពេលនេះនឹងបង គិតថាមានការលំបាកអីគេខ្លះដែរបង?

ខ៖ បងតាំងពីក្មេងរហូតមកដល់ពេលនឹងបងមិនសូវដែរលំបាកទេនឹង

ក៖ ចុះកាលពីក្មេងតាំងពីជំនាន់1979រហូងមកដល់ប៉ែតជាងនឹងបងធ្វើអីគេដែរបង មានគេអោយបងធ្វើអីទេ ដូចថាកាលដាច់ជំនាន់ពីជំនាន់ខ្មែរក្រហម?

ខ៖ អូ៎!អត់មានធ្វើអីផងនឹង

ក៖ ទាំងក្រុមគ្រួសារបងមានកាលលំបាកអីគេខ្លះដែរបង?

ខ៖ អត់ទេអូនបងមិនដែរមានកើតឡើងក្រុមគ្រួសារទេនឹង

ក៖ អូ៎!ចឹងហោសបង?

ខ៖ ហើយយើងនឹងក៏មិនមានធ្វើការអីគេដែរនឹង ក្រៅពីធ្វើស្រែនឹងធ្វើចំការអីនឹង

ក៖ ប៉ុន្តែពេលណុងបងនៅណាដែរទៅនបង?

ខ៖ បងនៅផ្ទះនឹង

ក៖ ប៉ុន្តែពេលណុងយើងចាប់ដីអីនៅហោសបង?

ខ៖ ចា៎!គេកាប់ដីដែរនឹង

ក៖ អត់ទេមិនមែនកាប់ដីទេ រកចាប់យកដីដើម្បីអោយមានផ្ទះស្នាក់នៅនឹងណាស់

ខ៖ មិនទាន់ទេអូននោះ លក្ខណះបងកើតមកបងនៅទីនេះរហូតនឹង

ក៖ អូ៎!ហោសបង?

ខ៖ គ្រាន់តែយើងឡើងទៅគេមិនមាត់ដែរនឹង ចុះកាលពីយើងនៅលំបាកអត់ចឹងទៅ

ក៖ អូ៎!បានបងមានអីទៀតទេ?

ខ៖ បងធ្លាប់ដាំបាយឡាយជាមួយពោត នឹងបងធ្លាប់ដែរនឹង

ក៖ ប៉ុន្តែកាលពីពេលណុងបងឯងនៅក្មេងៗទេណបង?

ខ៖ ចា៎!កាលណុងនៅក្មេងៗនឹង នឹងខ្ញុំធ្លាប់

ក៖  ចុះមានអីទៀតទេបងរហូតដល់ឆ្នាំកៅជាងចឹងណាស់ គ្រួសារបងមានបញ្ហាអីគេហើយបងធ្លាប់ មានបញ្ហាអីគេដែររឺក៏អត់មានទេបង?

ខ៖  ចា៎!អត់ទេអូន

ក៖  ចុះរហូតទាល់តែបងមានក្រុមគ្រសារបានបងមានអីកើតឡើងទេបង?

ខ៖
ចុះពេលដែរបងមានគ្រួសាររអីចឹងទៅក៏បងមិនមានការលំបាកអីគេទេដូចថាធម្មតាចឹងទៅណាស់

ក៖  ចឹងអត់មានការលំបាកអីទេ?

ខ៖  មានដែរតែកាលពីតូចនឹងនៅប៉ុណ្ណឹង ឥឡូវនឹងនៅដដែលនឹង

ក៖ ចឹងនៅតែសប្បាយរហូតនឹង?

ខ៖  អត់សប្បាយក៏នឹងអត់មានការលំបាកដែរ

ក៖  អូ៎!បាទបង?

ខ៖  សប្បាយពេករឺពិបាកពេកក៏ធម្មតានឹង

ក៖
ចុះពេលណាដែរបងគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់បងណាស់ ឧទាហរណ៍ដូចជា នៅពេលដែរបងការ រឺពេលដែរបងមានកូន រឺមួយក្រុមគ្រួសារដែរគិតថាធ្វើអោយបង សប្បាយចឹងណាស់?

ខ៖  មិនដឹងពេលណាទេមានតែជយបជុំក្រុមគ្រួសារចឹង សប្បាយនាំឡគ្នាដើរលេងអីចឹងទៅណាស់

ក៖  ដើរលេងជាមួយក្រុមគ្រួសារដែរទៅខេត្តអីចឹងហោសបង?

ខ៖  នឹងហើយលក្ខណះថាទៅខេត្តលេងអីចឹងទៅណាស់ នឹងទៅបុណ្យអីចឹងទៅយើងបានសប្បាយធ្វើ បុណ្យនឹង

ក៖  អូ៎!ចឹងហោសបង?

ខ៖ បងសប្បាយជាងគេនឹងគឺធ្វើបុណ្យនឹងហើយ

ក៖ ចុះនៅពេលបងការបងគិតថាបងសប្បាយដែរទេបង?

ខ៖ ដូចថាកាលពីជំនាន់ណុងដូចធម្មតាទេ មិនពីមិនសូវដឹងអីនឹង

ក៖ ម៉េចបានមិនដឹងអីបងគ្រាន់តែធំៗហើយនឹង

ខ៖ ដូចថាគេយកប្តីមកធ្វើអីគេ មានប្តីពិបាក រឺមួយក៏ស្រណុងអីអត់មានដឹងទេ

ក៖ ដល់ពេលឥឡូវនឹងដឹងហើយណា?

ខ៖ ឥឡូវនឹងទើបបានដឹងទាល់តែកូនមានបី ទៅបួនហើយទើបបានដឹងនឹង

ក៖ ចុះកាលពីក្មេងនឹងបងធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងចង់ធ្វើអីគេដែរទេបង?

ខ៖ ក្តីស្រម៉ៃរបស់បងនឹង កាលពីក្មេងនឹងបងគ្មានក្តីស្រម៉ៃផងនឹង

ក៖ អូ្ហ!ចឹងបងមិនមានការស្រម៉ៃទេ?

ខ៖ ស្រម៉ៃត្រឹមថាអោយក្រុមគ្រួសាររកស៊ីមានបាន កុំអោយបានបញ្ហាអីទៅបានហើយនឹង កុំអោយតែពិបាកវេទនាទៅបានហើយនឹង

ក៖
ចុះកាលពីបងនៅរៀននឹងបងតែងតែធ្លាប់មានក្តីប្រាថ្នាអីមួយថាធំឡើងចង់ធ្វើជាគ្រូបង្រៀន ធ្វើជា គ្រូពេទ្យ រឺប៉ូលីសអីមួយចឹងទៅបង?

ខ៖ បងមិនដឹងថាមានក្តីស្រម៉ៃថាចង់ធ្វើអីទេនឹងកាលពីជំនាន់មុននឹង

ក៖
ចុះបើចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗនឹងតើបងចង់ផ្តែផ្តាំអីទៅពួកគាត់ដែរបង?

ខ៖ បងគ្មានផ្តែផ្តាំអីទេ
គ្រាន់តែបចង់និយាយអីមួយហើយថាជំនាន់ក្មេងៗនឹងកុំអោយភ្លេចប្រពៃណីខ្មែរ យើងនឹង

ក៖ អូ្ហ!បាទបងចឹង?

ខ៖ លក្ខណៈសាសនាខ្មែរយើងនឹង សាសនាព្រះពុទ្ធអីនឹង កុំអោយភ្លេចប្រពៃណីខ្មែរយើងនឹងយើងចេះ គិតណាស់កុំអោយហួសទំនៀមទំលាប់គេនឹង ចង់អោយរក្សាវប្បធម៌ខ្មែរយើងអោយនៅស្ថិតស្ថេរ ចឹងទៅណាស់

ក៖ បាទបងមានអីទៀតទេ?

ខ៖ បងមានតែប៉ុណ្ណឹងទេបងណោះ?

ក៖ មានអីទៀតទេដែលចង់ផ្ដែផ្ដាំទៀតអត់បង?

ខ៖ នឹងការពារក្មេងៗកុំអោយដើរផ្លូវខុសនឹង

ក៖ ចុះបើសិនជាចង់អោយបងជៀសវាងវិញ តើបងចង់ផ្ដែផ្ដាំអីដើម្បីអោយពួកគាត់ជៀសវាងដែរបង?

ខ៖ ចង់អោយជៀសវាងនឹងគឺគ្រឿងញៀននឹងហើយអូន កុំអោយដើរចូលផ្លូវនឹង

ក៖ ចុះមានអីផ្ដែផ្ដាំទៀតអត់បង?

ខ៖ ហើយផ្ដែផ្ដាំកូនចៅអោយវាជិះម៉ូតូអោយវាបានសុវត្ថិភាពតាមផ្លូវអីចឹងទៅណាស់ នឹងរឿងគ្រោះថ្នាក់ចរាចរណ៍អីចឹងទៅណាស់

ក៖ អូ្ន!ដូចគេនិយាយថា ហួបស្រវឹងកុំបើកបរចឹងហីបង?

ខ៖ ចា៎!នឹងហើយហួបស្រវឹងកុំបើកបរអីចឹងទៅ ហើយបើកបរនឹងត្រូវការពារមើកគេមើលឯងនឹង នឹងមុនដើរឆ្លងផ្លូវនឹងត្រូវមើលគេមើលឯងអោយហើយនឹង

ក៖ បាទត្រូវបង?

ខ៖ ត្រូវមើលមុខមើលក្រោយ ពីព្រោះខ្លាចគ្រោះថ្នាក់នឹងវាទាន់ហាន់ណាស់

ក៖ បាទបងល្អបង មានអីទៀតទេ?

ខ៖ ចា៎!មានតែប៉ុណ្ណឹងទេអូន

ក៖ បាទជាចុងក្រោយនឹងអរគុណច្រើនបងដែរបានផ្ដល់ពេលវេលាដែរបានសំភាសន៍ពីប្រវត្តិរ

របស់បង

ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកុលទុកអោយបង ហើយនៅ ពេលដែរគេចេញជាឌីនឹងខ្ញុំនឹងយកមកចែកអោយបងចឹងទៅណាស់បង

បាទចឹងអរគុណច្រើនបង៕៕៕